AVSF
AGRONOMES & VÉTÉRINAIRES SANS FRONTIÈRES
RÉSEAU VSF INTERNATIONAL

CACU

UNI4COOP Eclosio LOUVAIN COOPERATION

DPA

ALiSEA





# បច្ចេកទេស ស្តីពី
# ផលិតកម្មល្ងសរីរាង្គ

USDA ORGANIC

## ការអនុវត្តតាមកសិអេកូឡូស៊ី

ថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០២៥



ដោយលោក **មាឌ សារឿន** ប្រធានគម្រោង

# មាតិកា




១ ដំណើរការចងក្រងសៀវភៅបច្ចេកទេសផលិតកម្មល្ងសរីរាង្គ

២ ការដំណើរការផលិតកម្មល្ងសរីរាង្គ

៣ បច្ចេកទេសផលិតកម្មល្ងសរីរាង្គ

៤ សញ្ញាណជោគជ័យ និងកត្តាប្រឈមនៃផលិតកម្មល្ងសរីរាង្គ

# ១. ដំណើរការបច្រកចៀវតៅ
# បច្ចេកទេសផលិតកម្មល្ងសរីរាង្គ

AVSF AGRONOMES & VÉTÉRINAIRES SANS FRONTIÈRES RÉSEAU VSF INTERNATIONAL

# ការចងក្រងសៀវភៅបច្ចេកទេសផលិតកម្មល្ងសរីរាង្គ

## ១) ការរៀបចំប្លង់សៀវភៅ

- ប្រជុំក្រុមការងារបច្ចេកទេស
- រៀបចំទម្រង់/គ្រោងឆ្អឹង
- កំណត់គោលបំណងនៃមេរៀន
- កំណត់ខ្លឹមសារ/មាតិកា

## ២) ការសិក្សាឯកសារយោង

- មេរៀនបច្ចេកទេសផលិតកម្មល្ង
- ច្បាប់ស្តង់ដារសរីរាង្គរបស់អឺរ៉ុប
- ច្បាប់ស្តង់ដារសរីរាង្គរបស់អាមេរិក

## ដំណើរការចងក្រងសៀវភៅបច្ចេកទេសផលិតកម្មល្ងសរីរាង្គ

## ៣)ការចុះសិក្សាពីការដាំដុះល្ងដោយកសិករ

- ព្រាងបញ្ជីសំណួរដឹកនាំសំខាន់ៗ
- ចុះជួបកសិករដាំដុះល្ង នៅខេត្តព្រះវិហារ
- ស្វែងយល់ពីការអនុវត្តបច្ចេកទេសដាំល្ង

## ៤)ការចងក្រងសៀវភៅបច្ចេកទេស

- សំយោគលទ្ធផលនៃការចុះប្រមូលព័ត៌មាន
- ចាប់ផ្តើមចងក្រងសៀវភៅបច្ចេកទេសដាំល្ង
- ផ្តល់មតិយោបល់ និងកែសម្រួលលើសេចក្តីព្រាងនៃសៀវភៅបច្ចេកទេសដោយក្រុមការងារ
- បង្ហើយ និងបោះពុម្ពសៀវភៅបច្ចេកទេសដាំល្ង

# ២. ការដំណើរការផលិតកម្មល្បសរីរាង្គ

AVSF
AGRONOMES & VÉTÉRINAIRES SANS FRONTIÈRES
RÉSEAU VSF INTERNATIONAL

# ជំហានសំខាន់ៗនៃផលិតកម្មលូសរីរាង្គ

| ជំហាន | សកម្មភាព |
|---|---|
| **ជំហានទី ១៖ កំណត់ និងអនុម័តជ្រើសរើសកសិករ និងដីដាំលូ** | ❖ ដាក់ពាក្យចូលជាសមាជិកក្រុមផលិតលូសរីរាង្គ<br>❖ ត្រួតពិនិត្យគុណវុឌ្ឍិរបស់កសិករ និងការអនុលោមលើដីស្រែដែលបានអនុម័តដោយអ្នកត្រួតពិនិត្យ<br>❖ ប្ដេជ្ញាចិត្តរបស់កសិករក្នុងការគោរពតាមច្បាប់ផលិតកម្មសរីរាង្គ |
| **ជំហានទី ២៖ ការបណ្ដុះបណ្ដាលបច្ចេកទេសដល់កសិករ** | ❖ បង្រៀនពីបច្ចេកទេសផលិតកម្មលូសរីរាង្គ<br>❖ បង្រៀនពីការកត់ត្រាសៀវភៅកសិករលើផលិតកម្មលូសរីរាង្គ |
| **ជំហានទី ៣៖ ការអនុវត្តបច្ចេកទេសដាំដុះលូសរីរាង្គ** | ❖ រយៈពេលនៃការកែប្រែដីពីដីអសរីរាង្គទៅដីសរីរាង្គ<br>❖ ការកំណត់តំបន់ការពារ<br>❖ ការជ្រើសរើសគ្រាប់ពូជ<br>❖ ការរៀបចំដី<br>❖ វិធីសាស្ត្រដាំដុះ<br>❖ ការថែទាំដំណាំ<br>❖ ការប្រមូលផល និងក្រោយពេលប្រមូលផល |
| **ជំហានទី ៤៖ ការលក់លូសរីរាង្គ** | ❖ ការដឹកជញ្ជូនលូសរីរាង្គទៅកន្លែងប្រមូលផ្ដុំដែលបានកំណត់<br>❖ ការប្រើប្រាស់សំបកវេចខ្ចប់ថ្មី ឬស្អាតដាក់លូ<br>❖ ការកត់ត្រាពីបរិមាណលូលក់ ដើម្បីផ្ទៀងផ្ទាត់<br>❖ ការរក្សាទុករាល់ឯកសារលក់លូសរីរាង្គ |

**ការត្រួតពិនិត្យផ្ទៃក្នុង**

**ការត្រួតពិនិត្យប្រចាំឆ្នាំដោយស្ថាប័នឯករាជ្យ**

# ៣.បច្ចេកទេស
# ផលិតកម្មល្ងសរីរាង្គ

# សេចក្តីផ្តើម



- ល្ង ជាដំណាំមួយដែលមានវ័យចាស់ៗជាងគេ នៅលើពិភពលោក *(រកឃើញដំបូងគេនៅឧបទ្វីបអារ៉ាប៊ិច)*។
- ល្ង ជាប្រភេទដំណាំដែលមានភាពធន់ទ្រាំទៅនឹងភាពរាំងស្ងួត ដោយសារប្រព័ន្ធឫសរបស់វាចាក់ចូលជ្រៅទៅក្នុងដី។
- ល្ង ជារុក្ខជាតិដែលសម្បូរសារធាតុប្រេងខ្ពស់(៥០%) ។
- ដំណាំល្ង ផ្តល់ផលប្រយោជន៍ជាច្រើន និងសម្បូរដោយសារធាតុចិញ្ចឹម សម្រាប់ទ្រទ្រង់រាងកាយមនុស្ស និងសត្វ៖
  - ប្រូតេអ៊ីន ជាតិដែក កាល់ស្យូម កាបូនអ៊ីដ្រាត វីតាមីនបេ១(B1)
  - ជាវត្ថុធាតុដើម ផលិតសាប៊ូដុសខ្លួន សាប៊ូកក់សក់ ថ្នាំលាប ទឹកអប់
  - ផលិតជា ឱសថក្នុងការព្យាបាលជំងឺផ្សេងៗ និងថ្នាំកម្ចាត់សត្វល្អិត

# ភាពខុសគ្នារវាង ការដាំល្ងសរីរាង្គ និងការដាំល្ងតាមទម្លាប់

## ការដាំល្ងសរីរាង្គ

សំដៅលើការអនុវត្តតាមដូចខាងក្រោម៖

- គោលការណ៍ធម្មជាតិ
- តាមស្តង់ដារសរីរាង្គណាមួយ
- មិនប្រើធាតុចូលគីមី(ជីគីមី ថ្នាំពុលកសិកម្ម)
- នាំឱ្យប៉ះពាល់ដល់និរន្តរភាពនៃប្រព័ន្ធជីវចម្រុះ សកម្មភាពជីវសាស្ត្រដី សុខុមាលភាពមនុស្ស និងសត្វ






## ការដាំល្ងតាមទម្លាប់

ជាការដាំដុះល្ងដែល

- មិនតាមលក្ខខណ្ឌតម្រូវរបស់ស្តង់ដារសរីរាង្គ
- ប្រើធាតុចូលកសិកម្ម ដែលមានផ្ទុកសារធាតុគីមីហាមឃាត់ (ជីគីមី ថ្នាំសម្លាប់ស្មៅ សត្វល្អិត ជំងឺ)






# ផលប្រយោជន៍នៃការដាំល្ងសរីរាង្គ



លក់បានតំលៃខ្ពស់សមរម្យ






សុវត្ថិភាពចំណីអាហារ




កាត់ចំណាយ
ទិញជីគីមី ថ្នាំពុលកសិកម្ម...



កាត់ចំណាយការព្យាបាលជំងឺ



រក្សាជីវចម្រុះ

# ៣.១ រយៈពេលនៃការកែប្រែដី និងតំបន់ការពារ

## រយៈពេលនៃការកែប្រែដី

| ឆ្នាំទី ១ (១២ខែ) | ឆ្នាំទី ២ (១២ខែ) | ឆ្នាំទី ៣ (១២ខែ) | ក្រោយរយៈពេល ៣ឆ្នាំ (៣៦ ខែ) |
|---|---|---|---|
| ✗ | ✗ | ✗ | ✓ |
| រយៈពេលនៃការកែប្រែដីបានពេញលេញ៖ ៣៦ ខែ | | | ដំណាំលូ អាចលក់ជា "សរីរាង្គ" |

## តំបន់ការពារ

សំដៅដល់តំបន់ដែលខណ្ឌចែកព្រំប្រទល់ រវាងទីតាំងផលិតកម្មកសិកម្មសរីរាង្គ និងទីតាំងផលិតកម្មកសិកម្មតាមទម្លាប់។

- ជ្រើសរើសទីតាំងដាំលូសរីរាង្គឱ្យខ្ពស់ជាង ទីតាំងផលិតកម្មកសិកម្មតាមទម្លាប់អ្នកជិតខាង
- ធ្វើទំនប់ ឬលើកភ្លឺឱ្យបានធំ និងរឹងមាំ
- ដាំរុក្ខជាតិធ្វើជារបងរស់ ដើម្បីការពារការសាយភាយសារធាតុគីមីហាមឃាត់ពីដំណាំអសរីរាង្គអ្នកជិតខាង
- ជីកប្រឡាយបង្ហូរ និងបញ្ចៀសទឹកជុំវិញចម្ការលូសរីរាង្គអ្នក ដើម្បីបង្វែរ ផ្លូវទឹកពីដំណាំអសរីរាង្គអ្នកជិតខាង។



# ៣.២ ការជ្រើសរើសពូជ





❶ **ល្ងស** ជាប្រភេទល្ងដែលមានអាយុកាលដាំដុះខ្លីជាង ឬស្រាលជាងល្ងខ្មៅ។ អាយុកាលរបស់វា មានរយៈពេលពី ៧០ថ្ងៃ ទៅ ៩០ថ្ងៃ ដោយគិតចាប់ថ្ងៃដាំដុះ រហូតដល់ថ្ងៃប្រមូលផល។

❷ **ល្ងខ្មៅ** ជាប្រភេទល្ងដែលមានអាយុកាលដាំដុះវែងជាង ឬក៏ធ្ងន់ជាងល្ងស។ អាយុកាលរបស់វា មានរយៈពេលពី ៩០ថ្ងៃ ទៅ ១៥០ថ្ងៃ ដោយគិតចាប់ថ្ងៃដាំដុះ រហូតដល់ថ្ងៃប្រមូលផល។

- ជាពូជសុទ្ធល្អ សាច់ណែនល្អ មិនស្អៀតស្វិត និងស្គាល់ប្រភពច្បាស់លាស់
- ផ្តល់ទិន្នផលខ្ពស់
- មានដំណុះចាប់ពី ៨៥%ឡើង ហើយគ្មានជំងឺ និងសត្វ ល្អិតបំផ្លាញ
- ធន់នឹងលក្ខខណ្ឌអាកាសធាតុ និងកត្តាចង្រៃនានាក្នុងតំបន់ដាំដុះ
- មានតម្រូវការច្រើននៅលើទីផ្សារ និងតំលៃខ្ពស់សមរម្យ។

## គ្រាប់ពូជល្ងដែលអនុញ្ញាតឱ្យដាំ

- ពូជល្ងសរីរាង្គ
- ករណីគ្មានពូជល្ងសរីរាង្គ គ្រាប់ពូជល្ងធម្មតាដែលគ្មានត្រាំ/ប្រឡាក់ថ្នាំគីមីហាមឃាត់ អនុញ្ញាតឱ្យដាំបាន ប៉ុន្តែត្រូវលាងសម្អាត មុនធ្វើការដាំដុះ។
- ការស្តុកគ្រាប់ពូជល្ង គឺត្រូវស្របតាមលក្ខខណ្ឌតម្រូវរបស់ស្តង់ដារសរីរាង្គដែលបានកំណត់ ដូចជា ប្រើសំបកបាវថ្មី/ស្អាត កន្លែងទុកល្ងគ្មានការឆ្លងសារធាតុគីមីហាមឃាត់។




## គ្រាប់ពូជល្ងហាមដាំ

- ហាមដាំគ្រាប់ពូជល្ង ដែលជាផលិតផលសារពាង្គកាយកែច្នៃសេ្បណោទិច(GMO)។
- ហាមដាំគ្រាប់ពូជល្ងអសរីរាង្គ ដែលមានត្រាំ/ប្រឡាក់ថ្នាំគីមី ឬលាយទ្បំធាតុកខ្វក់ ឬប្រព្រឹត្តិកម្មគីមី ។

# ៣.៣ ការរៀបចំដី

## ក) ការជ្រើសរើសទីតាំង

- ដីទួល ផ្ទៃរាបស្មើ និងមានប្រព័ន្ធបង្ហូរទឹកបានល្អ (មិនជាំទឹក)។
- ដីដែលមានជីជាតិល្អ ជាពិសេសដីល្បាប់។
- ចៀសវាងដីទំនាបដែលមិនជ្រាបទឹកល្អ(ជាំទឹក) ឬគ្មានប្រព័ន្ធ រំដោះទឹក។





### ⚠ បម្រាម/លក្ខខណ្ឌតម្រូវ

- ត្រាក់ទ័រ ឬគោយន្តភ្ជួររាស់ មិនត្រូវប្រើប្រាស់លាយឡំគ្នា រវាងចម្ការល្ហុសរីរាង្គ និងដំណាំអសរីរាង្គឡើយ។
- ករណីប្រើប្រាស់លាយឡំគ្នា ត្រាក់ទ័រ ឬគោយន្តភ្ជួរនោះ ត្រូវលាងសម្អាតដោយប្រើទឹកស្អាត ឬវិធីផ្សេងៗ ដែលធានាថាគ្មានការឆ្លងសារធាតុគីមីហាមឃាត់ មុននឹងយកទៅភ្ជួររាស់ដីចម្ការល្ហុសរីរាង្គ។

## ខ) ការៀបចំដី

- ❖ ភ្ជួរដីឱ្យបានឆាប់ នៅពេលដីសើម។
- ❖ ភ្ជួររាស់យ៉ាងហោចពី ២ ឬ ៣ដង មុននឹងធ្វើការដាំដុះល្ហ៖
  - ភ្ជួរលើកទី ១៖ ជម្រៅពី ២ ទៅ ២,៥ តឹក ហើយហាលដីបាន ៧-១០ថ្ងៃ មុននឹងភ្ជួរលើកទី២។
  - ភ្ជួរលើកទី ២៖ ជម្រៅ ១,២ ទៅ ២ តឹក។
  - ករណី ដីមិនសូវសម្បូរជីជាតិ ត្រូវដាក់ជីទ្រាប់បាត (ជីធម្មជាតិ ជីកំប៉ុស្ដិ៍ លាមកសត្វ...) ដោយពង្រាយឱ្យពេញដី មុនពេលចាប់ផ្ដើមភ្ជួរ។
  - ក្រោយភ្ជួររួច ត្រូវរាស់ដីឱ្យបានពី ២ ទៅ ៣ដង ធ្វើបែបនេះឱ្យដីម៉ត់ល្អ និងដីធូរមិនក្ដាំងរឹង។
- ❖ ឆ្វូតចង្ហូរជារង និងរៀបចំប្រព័ន្ធរំដោះទឹកនៅជុំវិញស្រែ។

# ៣.៤ វិធីសាស្ត្រដាំដុះ

### ❖ វិធីដាំ

- ○ គួរដាំល្ង ពេលដីមានសំណើមគ្រប់គ្រាន់
- ○ គួរលាយគ្រាប់ពូជល្ងជាមួយដីម៉ត់ល្អ ដើម្បីព្រោះគ្រាប់ល្ង បានស្មើល្អ និងឯកសណ្ឋាន
- ○ គំលាតជួរពី ៥០-៦០ស.ម និងចន្លោះគុម្ពពី ៣៥-៤៥ស.ម តែអាស្រ័យលើដីជាតិដី។
- ○ ដាំជាជួរ ជម្រៅរណ្ដៅដាំល្ងពី ២-៣,៨ស.ម ហើយ ១រណ្ដៅដាក់ ២-៣ គ្រាប់។
- ○ បរិមាណគ្រាប់ពូជល្ង ប្រើពី ៨-១០ គ.ក្រ/ហ.ត សម្រាប់ឆូតដាំជាជួរ និងពី ១០-១២ គ.ក្រ/ហ.ត សម្រាប់ព្រោះដោយដៃ។





### ❖ ពេលវេលាដាំដុះ

- ○ នៅរដូវវស្សា គេច្រើនដាំដុះនៅដើមរដូវវស្សា និងនៅពាក់កណ្ដាលរដូវវស្សា រវាងខែកញ្ញា និងខែតុលា។
- ○ នៅរដូវប្រាំង គេច្រើនដាំដុះនៅពាក់កណ្ដាលរដូវប្រាំង និងនៅចុងរដូវប្រាំង រវាងខែមីនា និងមេសា។

☞ **ចងចាំ៖** ការដាំល្ងនៅដើមរដូវវស្សា គឺត្រូវលៃយ៉ាងណាឱ្យពេលវេលាប្រមូលផល ចៀសផុតពេលដែលមានភ្លៀងច្រើន និងជាប់ៗគ្នា ដែលនាំឱ្យពិបាកទាំងការប្រមូលផល និងទាំងការហាលសម្ងួត។





# ៣.៥ ការពូនគល់ និងការគ្រប់គ្រងជីជាតិដី

## ក) ការរម្លស់កូន ការជម្រះស្មៅ និងពូនគល់

- រម្លស់កូន ត្រូវដកចេញ ក្រោយដាំ បាន ១៣ ថ្ងៃ ដោយរក្សាទុកកូន ២-៣ដើម/គុម្ព ដែលសុខភាពល្អ។
- ជម្រះស្មៅ និងពូនគល់ ចាប់ផ្តើមធ្វើបន្ទាប់ពីដាំបាន ២៣ ថ្ងៃ ហើយត្រូវធ្វើបាន ១- ២ដង/វដ្តជីវិតរបស់ល្ង។



### ⚠ បម្រាម/លក្ខខណ្ឌតម្រូវ

- ហាមប្រើថ្នាំពុលកសិកម្ម ឬសារជាតុគីមីហាមឃាត់ ក្នុងការបាញ់សម្លាប់ស្មៅ ឬព្រៃល្បាស់ ។
- គ្រប់សម្ភារ ឬឧបករណ៍(ចប កាំបិត បក ខ្វារ...) មិនត្រូវប្រើលាយឡំគ្នារវាងចម្ការល្ងសរីរាង្គ និងដំណាំអសរីរាង្គផ្សេងៗឡើយ ។
- ករណីប្រើលើដំណាំអសរីរាង្គ គ្រប់សម្ភារ ឬឧបករណ៍ទាំងនោះ ត្រូវតែលាងសម្អាតដោយទឹកស្អាត ឬវិធីផ្សេងៗ ដែលធានាថា គ្មានឆ្លងសារជាតុគីមីហាមឃាត់ មុននឹងយកមកប្រើលើចម្ការល្ងសរីរាង្គ។



## ខ) ការគ្រប់គ្រង និងការបង្កើតជីជាតិដី

ដើម្បីកែលម្អគុណភាពដី និងប្រើប្រាស់ដី ប្រកប ដោយប្រសិទ្ធភាពខ្ពស់ វិធានជីវចម្រុះត្រូវអនុវត្តៈ

- ការដាំដំណាំឆ្លាស់
- ដំណាំបង្វិល
- ការប្រើជីស្រស់
- ជីកំប៉ុស្តិ៍










### ⚠ បម្រាម/លក្ខខណ្ឌតម្រូវ

- ហាមប្រើជីគីមី និងជីសរីរាង្គដែលគ្មានលិខិតបញ្ជាក់ការទទួលស្គាល់ស្តង់ដារសរីរាង្គពីស្ថាប័នវាយតម្លៃស្តង់ដារសរីរាង្គឯករាជ្យខាងក្រៅ។




- ហាមប្រើលាកមសត្វដែលចិញ្ចឹមបែបអាជីវកម្ម (ផ្តល់ចំណីរោងចក្រ) កាកសំណល់ផ្ទះបាយ(ផ្ទុកសារជាតុគីមី)សម្រាប់ផ្សំជាជីធម្មជាតិ ឬជីកំប៉ុស្តិ៍ឡើយ។






- ហាមប្រើកាកសំណល់របស់មនុស្ស (លាមក ទឹកម៉ូត្រ សំណល់ពីបង្គន់ ។ល។) ដើម្បីជាជីសម្រាប់ប្រើលើដំណាំល្ងសរីរាង្គឡើយ។




- ហាមដុតកាកសំណល់សរីរាង្គក្នុងចម្ការដាំល្ងសរីរាង្គ។

# ៣.៦ ការគ្រប់គ្រងទឹក

ករណីគ្មានទឹកភ្លៀង ត្រូវស្រោចទឹក

- លើកទី១៖ នៅពេលចេញស្លឹក ៣-៤
- លើកទី២៖ នៅពេលជិតចេញផ្កា
- លើកទី៣ និង ៤៖ នៅពេលចេញផ្កា





☞ **ចំណាំ**៖ កម្រិតសំណើមច្រើនពេក មុនពេលដំណុះ និងដំណាក់កាលកំពុងចេញផ្កា វាមានផលប៉ះពាល់ខ្លាំងបំផុត ពីព្រោះអាចបង្កឱ្យកើតជំងឺផ្សិត និងជំងឺរលួយបានយ៉ាងងាយទៅលើគ្រាប់ ឫស និងផ្កា។

⚠ **បម្រាម/លក្ខខណ្ឌតម្រូវ**

- ហាមប្រើទឹកដែលមានធ្លងសារធាតុគីមីហាមឃាត់ យកមកស្រោចស្រពលើដំណាំល្ងសរីរាង្គ។
- ហាមប្រើប្រាស់ទឹកលើដី និងទឹកក្រោមដីសម្រាប់ធ្វើការស្រោចស្រពដំណាំល្ងហួសកម្រិតដែលធ្វើឱ្យរីងស្ងួតអស់( គ្មានទឹកសម្រាប់សត្វផឹក ឬងាប់ត្រី ) និងបាត់បង់តុល្យភាពនៃប្រព័ន្ធអេកូឡូស៊ី និងជីវចម្រុះក្នុងតំបន់។





# ៣.៧ ការគ្រប់គ្រងសមាសភាពចង្រៃ

## ក) ការគ្រប់គ្រងសត្វល្អិតចង្រៃ




**គន្លឹះនៃការអនុវត្តល្អក្នុងវិធានការណ៍ការពារ**

- ការប្រើពូជដែលធន់នឹងសត្វល្អិត
- ការដាំដំណាំឆ្លាស់
- ការដាំដំណាំរង្វិលជុំ
- ការសាបព្រួសទាន់ពេលវេលា
- ការធ្វើអនាម័យដំណាំ
- ការរក្សាពពួកសត្វល្អិតមានប្រយោជន៍នៅក្នុងចម្ការល្ង។




## ខ) ការគ្រប់គ្រងជំងឺ

**គន្លឹះនៃការអនុវត្តល្អក្នុងវិធានការណ៍ការពារ**

- ជ្រើសរើសពូជដែលធន់នឹងជំងឺ
- ហាលដីឱ្យបានល្អ
- ដាំដំណាំឆ្លាស់ ឬចម្រុះ
- ដាំដំណាំបង្វិល។

### ⚠ បម្រាម/លក្ខខណ្ឌតម្រូវ

- ហាមប្រើថ្នាំពុលគីមី ដើម្បីកម្ចាត់ជំងឺ និងសត្វល្អិតចង្រៃ
- គ្រប់វត្ថុធាតុដើមដែលផ្សំជាថ្នាំពុលធម្មជាតិ សម្រាប់កម្ចាត់សត្វល្អិត ឬជំងឺ មិនត្រូវឆ្លងសារធាតុគីមី ឬលាយឡំជាតុកខ្វក់។
- ហាមប្រើថ្នាំជក់ (ថ្នាំខ្លាំង) ដែលមានសារជាតុនីកូទីន សុទ្ធមកធ្វើជារុក្ខជាតិផ្សំសម្រាប់កម្ចាត់សត្វល្អិតចង្រៃ។





# ៣.៨ ការប្រមូលផល និងក្រោយពេលប្រមូលផល

## ក) ការប្រមូលផល

### សញ្ញានៃដំណាំល្ងដែលអាចប្រមូលបាន

- ផ្លែល្ងទុំបាន ៧៥% និងប្រែជាពណ៌ត្នោត ហើយផ្លែត្រៀមបែកមាត់ចាប
- ដំណាំល្ងចាប់ផ្តើមស្ងួតនៅខាងលើកន្លែងដែលត្រូវបានកាត់/ប្រមូលផល
- ដើម និងស្លឹកបានប្រែពណ៌ពីបៃតង ទៅលឿង ហើយពីលឿង ទៅក្រហម
- ស្លឹកក៏ចាប់ផ្តើមជ្រុះពីដើម។



### វិធីប្រមូលផល

- ត្រូវបានធ្វើឡើងដោយដៃ ដោយប្រើកណ្តៀវ កាំបិត ឬឧបករណ៍ផ្សេងៗ ដើម្បីកាត់ដើមល្ងដែលទុំនោះ។
- តែគួរចៀសវាងការប្រមូលផលល្ង ដោយដកទាំងឫស ពីព្រោះអាចឆ្លងសារធាតុកខ្វក់ ឬបង្កកើតជំងឺផ្សិត(Aflatoxin)។
- បន្ទាប់មក ចងដើមល្ងជាកណ្តាប់ ឬបាច់ឱ្យតឹង រួចដាក់បញ្ឈរត្រង់។
- កណ្តាប់ត្រូវចងឱ្យតឹងក្នុង ២ ឬ ៣ថ្ងៃ។
- គួរចៀសវាងដាក់កន្ស្រាមផ្លែផ្កាប់ចុះក្រោម ឬប៉ះពាល់ជាមួយដី ដែលនាំឱ្យបាត់បង់ទិន្នផល ដោយសារចាប់ផ្តើមបែកលើដី។





# ៣.៨ ការប្រមូលផល និងក្រោយពេលប្រមូលផល (ត)

## ខ) ក្រោយពេលប្រមូលផល

### ❖ ការរៀបចំទីតាំងហាល និងការហាលសំងួត

- ទីតាំងហាលដែលគ្មានហានិភ័យ ស្មើល្អ ទួលខ្ពស់ គ្មានជាំទឹក
- យកតង់ក្រាលពីក្រោម និងសម្រាប់ក្របពីលើនៅពេលយប់ និងពេលភ្លៀង។
- យកបាច់ល្ងប្រមូលផលរួច ដាក់តម្រៀបបញ្ឈរឱ្យត្រង់ចំពន្លឺព្រះអាទិត្យ និងខ្យល់។
- ហាលបាន ២ ឬ ៣ថ្ងៃរួច ត្រូវបង្វិលបាច់ល្ងណាដែលមិនសូវចំពន្លឺល្អ ឱ្យចំពន្លឺម្តង។
- ក្នុងរយៈពេល ២ សប្តាហ៍ បាច់ល្ងនោះ អាចធ្វើការបោកបែនបានហើយ។

### ❖ ការបោកបែន ការសម្អាត និងការទុកដាក់គ្រាប់ល្ង

- រៀបចំកន្លែងបោកបែន និងសំអាតល្ងសរីរាង្គ ត្រូវនៅឱ្យដាក់ដោយឡែកពីគេ។
- ត្រូវគោះ ឬវាយបាច់ល្ងរហូតដល់គ្រាប់ល្ងជ្រុះអស់។
- រោយសំអាត ដោយដៃ ឬដោយឧបករណ៍រោយ។
- ពិនិត្យឃើញកម្រិតសំណើមត្រឹម៧% ចុះ ទើបវេចខ្ចប់គ្រាប់ល្ងដោយសំបកវេចខ្ចប់ថ្មី/ស្អាត
- រក្សាទុកគ្រាប់ល្ងសរីរាង្គ នៅកន្លែងដាច់ពីគេ ដែលសុវត្ថិភាព និងស្អាត។













### ⚠ បម្រាម/លក្ខខណ្ឌតម្រូវ

- ➢ សម្ភារ/ឧបករណ៍(កណ្តៀវ ល្អី តង់ គោយន្តដឹក...) ដែលប្រើក្រោយពេលប្រមូលផល មិនត្រូវប្រើលាយឡំគ្នា រវាងល្ងសរីរាង្គ និងកសិផលអសរីរាង្គ។
- ➢ ក្នុងករណីប្រើសម្ភារ/ឧបករណ៍នោះចូលគ្នា ត្រូវលាងសម្អាតឱ្យបានស្អាត មុននឹងយកមកប្រើលើល្ងសរីរាង្គ ។
- ➢ ហាមប្រើសម្ភារវេចខ្ចប់ (សំបកបេ...) ដែលធ្លាប់វេចខ្ចប់ផលិតផលគីមី យកមកវេចខ្ចប់ល្ងសរីរាង្គ ។

# សញ្ញាណជោគជ័យ និង
# កត្តាប្រឈមនៃផលិតកម្មល្ងសរីរាង្គ

# សញ្ញាណជោគជ័យ និងភក្តាប្រឈមនៃផលិតកម្មល្ងសរីរាង្គ

## ក) សញ្ញាណជោគជ័យ

- ❑ ការចូលរួមរបស់កសិករសរុបក្នុងឆ្នាំ ២០២៥ មាន ៣១ គ្រួសារ (ទិន្នផលរំពឹងជាង ៧ តោន) បើធៀបនឹងឆ្នាំ ២០២៤ មាន ២២ គ្រួសារ (ទិន្នផលទទួលបានជិត ៣ តោន)។
- ❑ ក្នុងចំណោមកសិករសរុបឆ្នាំ ២០២៥ កសិករសរីរាង្គមានចំនួន ១៣ គ្រួសារ (ទិន្នផលរំពឹងជាង ៣ តោន) បើធៀបនឹងឆ្នាំ ២០២៤ មាន ៣ គ្រួសារ (ទិន្នផលទទួលបាន ៣១,៥ គីឡូក្រាម)។
- ❑ បានចុះអនុស្សរណៈយោបល់រយៈពេល ៣ ឆ្នាំជាមួយអ្នកទិញនៅខាងក្រៅប្រទេស លើកសិផលល្ងសរីរាង្គ។







# ភាពជោគជ័យ និងកត្តាប្រឈមនៃផលិតកម្មល្ងសរីរាង្គ (ត)

## ២) កត្តាប្រឈម

- ដំណើរការបញ្ជូលដីថ្មីក្នុងក្រុមផលិតកម្មល្ងសរីរាង្គមានភាពស្មុគស្មាញ និងចំណាយខ្ពស់ យោងតាមច្បាប់សរីរាង្គថ្មីរបស់សហភាពអឺរ៉ុប។
- ការដាំដុះល្ងសរីរាង្គពិបាកជាងការដាំដុះដំណាំសរីរាង្គផ្សេងៗ (ស្រូវ ដំឡូងមី ស្វាយចន្ទី...) ជាពិសេសទៅលើការគ្រប់គ្រងស្មៅ ការប្រមូលផល។
- ដំណាំល្ងជាដំណាំបន្ទាប់បន្សំ ដែលកសិករភាគមិនមានដីជាក់លាក់សម្រាប់ការដាំដុះល្ងទេ បើធៀបជាមួយស្រូវ ដំឡូងមី ស្វាយចន្ទី ដែលមានផលលំបាកក្នុងអនុវត្តដំណាំល្ងសរីរាង្គ។

# សូមអរគុណចំពោះការយកចិត្តទុកដាក់របស់លោកអ្នក!

អង្គការអ្នកកសិកម្មសាស្ត្រ និងពេទ្យសត្វគ្មានព្រំដែន (AVSF)

#24, Street 79BT, Village of Chamroeun Phal, Sangkat Boeung Tumpon 1, Khan  Meanchey, PO Box 902, Phnom Penh, Cambodia

Tel/Fax: +855 (0)23 215 037/ Email: avsf@online.com.kh / www.avsf.org/ www.ruralter.org

*Association with recognized charitable status*